# អនុស្សារណៈនៃការយោគយល់គ្នា
# រវាង
# ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
# និង
# ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់នៅកម្ពុជា

# ស្តីពី
# ការអនុវត្តកម្មវិធីនៅក្នុងប្រទេសកម្ពុជា
# "បទដ្ឋានសង្គមនិងការងារនៅក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ
# នៅក្នុងតំបន់អាស៊ី"

១២

អនុស្សារណៈនៃការយោគយល់គ្នានេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា

**រវាង**

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (អគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ) ចាប់ពីពេលនេះតទៅហៅកាត់ថា "MLVT"។

**និង**

ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់នៅកម្ពុជា ( Dag-Hammarskjoeld-Weg 1-5 65760 Eschborn) ចាប់ពីពេលនេះតទៅហៅកាត់ថា "GIZ កម្ពុជា"។

ទាក់ទងនឹងគម្រោង៖

"កម្មវិធីបទដ្ឋានសង្គម និងការងារនៅក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ នៅក្នុងតំបន់អាស៊ី" ចាប់ពីពេលនេះតទៅហៅកាត់ថាគម្រោង "GIZ, SLSG"

## ដោយហេតុថា

កម្មវិធីបទដ្ឋានសង្គម និងការងារនៅក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅក្នុងតំបន់អាស៊ីរបស់ GIZ (GIZ, SLSG) មានបំណងជួយដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MLVT) នៅក្នុងកិច្ចខិតខំដើម្បីលើកកម្ពស់លក្ខខណ្ឌការងារ ក្នុងឧស្សាហកម្មវាយនភណ្ឌ និងកាត់ដេរ នៅកម្ពុជា។

MLVT ត្រៀមខ្លួនរួចជាស្រេច និងមានឆន្ទៈក្នុងការទទួលយកការជួយគាំទ្រពី GIZ, SLSG សម្រាប់ពង្រឹងសមត្ថភាពរបស់ក្រសួងក្នុងការជួយគាំទ្រដល់វិស័យវាយនភណ្ឌ និងកាត់ដេរ ឱ្យក្លាយជាផ្នែកមួយនៃវិស័យឧស្សាហកម្មដែលមានដំណើរការល្អ និងស្របតាមគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងតម្រូវការនៃការអភិវឌ្ឍ ជាមួយនឹងសុខុមាលភាពរបស់កម្មករនិយោជិត។ ទំនាក់ទំនងពី MLVT ទៅកាន់ GIZ គប្បីធ្វើឡើងតាមរយៈលោក **អ៊ុក ចាន់ធូ** ប្រធាននាយកដ្ឋានអធិការកិច្ចការងារ អ៊ីមែល៖ ouk_chantou@yahoo.com។

## ១. រយៈពេល

រយៈពេលនៃកិច្ចសហប្រតិបត្តិការដែលមានចែងក្នុងអនុស្សារណៈនៃការយោគយល់គ្នានេះ គឺចាប់ពីខែមករា ឆ្នាំ២០១៦ ដល់ ខែមករា ឆ្នាំ២០១៨។

## ២. គោលបំណងនៃគម្រោង និងលទ្ធផលគ្រោងទុក

គោលបំណងនៃកិច្ចសហប្រតិបត្តិការនេះគឺ៖

- MLVT ជួយគាំទ្រដល់បណ្តាស្ថាប័នរដ្ឋនិងឯកជន ដើម្បីអនុវត្តទម្រង់សមស្របផ្នែកការផ្លាស់ប្តូរព័ត៌មាន ការពិភាក្សា និងកិច្ចសហប្រតិបត្តិការនៅតាមរោងចក្រ ក៏ដូចជានៅថ្នាក់ជាតិ និងថ្នាក់តំបន់ក្នុងបំណង

ជួយគាំទ្រឱ្យមានការគោរពតាមបទដ្ឋានការងារ និងសង្គម ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន និងបានទទួលស្គាល់។

- MLVT ទទួលយកការជួយជ្រោមជ្រែងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពី GIZ កម្ពុជា តាមរយៈគម្រោងនេះ ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួន។ ហេតុនេះ គម្រោងនឹងផ្តោតការយកចិត្តទុកដាក់លើការបង្កើតឱ្យមានប្រព័ន្ធអធិការកិច្ចការងារប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ដែលអាចជឿទុកចិត្តបានពីសាធារណជន។ MLVT ក្រោមការជួយគាំទ្រពីគម្រោង GIZ, SLSG មានបំណងជួយចូលរួមវិភាគទានគួរឱ្យកត់សម្គាល់ ក្នុងការបង្កើតប្រព័ន្ធអធិការកិច្ចគួរជាទីទុកចិត្ត និងមានតម្លាភាព សម្រាប់ការអនុវត្តបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ។ ប្រព័ន្ធនេះនឹងជួយពង្រឹងការអនុវត្តបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ហើយទីបំផុតនឹងនាំឱ្យមានផលិតកម្មកាន់តែប្រសើរ។

លទ្ធផលរំពឹងទុករួមមាន៖

- កម្មករនិយោជិត និងគណៈគ្រប់គ្រង រួមទាំងអ្នកតំណាងផ្នែកដែលពាក់ព័ន្ធរបស់រោងចក្រ (ដូចជាផ្នែកធនធានមនុស្ស ផ្នែកគុណភាពជាដើម) ត្រូវជួបប្រជុំគ្នាជាទៀងទាត់ ក្នុងបំណងដើម្បីអនុវត្តបទដ្ឋានការងារ និងសង្គម ដូចជាដើម្បីចែករំលែកព័ត៌មាន និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់និងគុណសម្បត្តិនៃការអនុវត្តបទដ្ឋានសង្គម និងការងារ ដែលរាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់។
- ការផ្សារភ្ជាប់រវាងការប្រាស្រ័យទាក់ទងគ្នាកាន់តែប្រសើរ ជាមួយនឹងទំនាក់ទំនងនៃការគ្រប់គ្រងកម្មករនិយោជិតរួមទាំងផលប៉ះពាល់ដែលអាចកើតមានមួយចំនួនទៅលើផលិតភាព ត្រូវបានពិនិត្យតាមរយៈការសិក្សាស្រាវជ្រាវដែលត្រូវបានចាត់តាំងរួមគ្នាដោយ MLVT និង GIZ កម្ពុជា។
- យុទ្ធសាស្ត្រមួយដើម្បីភាពប្រកួតប្រជែងប្រសើរឡើង ដោយគិតគូរអំពីការគោរពតាមបទដ្ឋានការងារ និងសង្គម សម្រាប់វិស័យវាយនភណ្ឌ និងកាត់ដេរនៅកម្ពុជា នឹងត្រូវបង្កើតឡើងដោយមានការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធនានា (ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម និយោជក និង សមាគមឧស្សាហកម្មនានា ព្រមទាំងសហជីពកម្មករនិយោជិត)។
- កំណត់ពីចំណុចខ្សោយ និងតម្រូវការចាំបាច់នានារបស់ MLVT ដើម្បីបង្កើតឱ្យមានប្រព័ន្ធអធិការកិច្ចការងាររឹងមាំមួយ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ក្នុងការធ្វើអធិការកិច្ចការងារនៅក្នុងវិស័យនេះ (ជំនាញនីតិវិធីបច្ចេកវិទ្យា)។

## ៣. ការរួមចំណែករបស់ GIZ កម្ពុជា

រដ្ឋាភិបាលសហព័ន្ធអាល្លឺម៉ង់នឹងផ្តល់ប្រាក់ចំនួនអតិបរមា ១,២៣៧,០៤០ អឺរ៉ូ (មួយលានពីររយសាមសិបប្រាំពីរពាន់សែសិប) ដល់ GIZ កម្ពុជា។ ចំនួនទឹកប្រាក់នេះ ត្រូវរួមបញ្ចូលទាំងការចំណាយនានារបស់ GIZ កម្ពុជា ពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះផងដែរ។ តាមកិច្ចសហប្រតិបត្តិការបច្ចេកទេសនេះ មូលនិធិនឹងត្រូវគ្រប់គ្រងដោយការិយាល័យ GIZ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

### ការផ្តល់អ្នកជំនាញការ៖

GIZ កម្ពុជា ត្រូវផ្តល់ជូនដល់គម្រោងនេះនូវ៖

- អ្នកជំនាញការម្នាក់ ធ្វើជាអ្នកគ្រប់គ្រងគម្រោង។ បុគ្គលរូបនេះ នឹងធ្វើការជាអ្នកប្រឹក្សាដល់ MLVT ហើយនឹងធ្វើការសម្របសម្រួល និងដឹកនាំបេសកកម្មរបស់ក្រុមអ្នកជំនាញការថ្នាក់ជាតិដែលពាក់ព័ន្ធក្នុងគម្រោងនេះ។
- ទីប្រឹក្សាគោលនយោបាយជាតិម្នាក់ និងអ្នកសម្របសម្រួលបច្ចេកទេសជាតិម្នាក់។
- ជំនាញការអន្តរជាតិ និងជាតិដែលបម្រើការងាររយៈពេលខ្លី សម្រាប់ធ្វើការសិក្សា ការបណ្តុះបណ្តាល និងការគាំទ្រផ្នែកបច្ចេកទេស។

### ការបណ្តុះបណ្តាលមូលដ្ឋាន និងការបណ្តុះបណ្តាលកម្រិតខ្ពស់

GIZ កម្ពុជា ត្រូវរៀបចំការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា សម្រាប់មន្ត្រីមកពី MLVT និងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធដទៃទៀត ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគាត់ ជាពិសេសទាក់ទងនឹងការអនុវត្តបទដ្ឋានសង្គមនិងការងារ ព្រមទាំងការបង្កើតប្រព័ន្ធអធិការកិច្ចការងារនៅក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ។

### សម្ភាររបស់គម្រោង៖

សម្ភាររបស់គម្រោង ជាពិសេសគឺយានយន្តរបស់គម្រោង នឹងត្រូវផ្ទេរឱ្យទៅនាយកដ្ឋានអធិការកិច្ចការងាររបស់ MLVT នៅពេលចុងបញ្ចប់នៃគម្រោង។

### ចំណាយផ្នែកប្រតិបត្តិការ និងរដ្ឋបាល

GIZ កម្ពុជា ត្រូវទទួលខុសត្រូវលើចំណាយផ្នែកប្រតិបត្តិការ និង/ឬ រដ្ឋបាលដែលជាការចូលរួមចំណែករបស់ភាគីអាល្លឺម៉ង់ទៅក្នុងកម្មវិធីនេះ ក៏ដូចជាការចំណាយដែលកើតឡើងពីការអនុវត្តគម្រោងដោយផ្ទាល់ផងដែរ។

## ៤. ការចូលរួមចំណែករបស់ MLVT

MLVT គឺជាដៃគូផ្នែកនយោបាយរបស់គម្រោងក្នុងប្រទេសកម្ពុជា ហើយក៏នឹងដើរតួជាទីភ្នាក់ងារប្រតិបត្តិដ៏ចំបងរបស់គម្រោង ហើយ MLVT មានសិទ្ធិទាមទារសេវាដែលខ្លួនមានសិទ្ធិទទួលបានពី GIZ កម្ពុជា។

MLVT នឹង៖

- ផ្តល់មន្ត្រីសម្រាប់ជួយដល់ការអនុវត្តគម្រោង ដែលជាការភ្ជាប់ទំនាក់ទំនងជាមួយក្រុមជំនាញជាតិនិងអន្តរជាតិ
- បញ្ជូនគណៈប្រតិភូទៅចូលរួមការប្រជុំស្តីពីគម្រោងនេះ
- ជួយសម្រួលដល់បុគ្គលិក GIZ កម្ពុជា ដែលពាក់ព័ន្ធក្នុងគម្រោងនេះ ឱ្យមានលទ្ធភាពទំនាក់ទំនងជាមួយក្រសួង និងដៃគូពាក់ព័ន្ធផ្សេងទៀតទៅតាមការចាំបាច់សម្រាប់ការអនុវត្តគម្រោងនេះ

- ជួយសម្រួលដល់អ្នកជំនាញក្នុងការចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល និងជួយជ្រោមជ្រែង GIZ កម្ពុជា ក្នុងការទំនាក់ទំនងទៅអ្នកចូលរួមមកពីស្ថាប័នដទៃទៀតរបស់កម្ពុជា ដែលពាក់ព័ន្ធនឹងគោលបំណង របស់គម្រោង
- ផ្តល់បន្ទប់ការិយាល័យសម្រាប់អ្នកសម្របសម្រួលគម្រោងនៅ MLVT និង
- ត្រូវធានាឱ្យមានការសម្របសម្រួលជាមួយ គម្រោងបទដ្ឋានសង្គម និងការងារជាទូទៅនៅកម្ពុជា។

ភាគីទាំងពីរ ដែល MLVT តំណាងដោយ **ឯកឧត្តម អ៊ុំ មាន** និង GIZ កម្ពុជា តំណាងដោយ លោក **Adelbert Eberhardt** និងលោកស្រីបណ្ឌិត **Monika Lüke** ចុះហត្ថលេខាលើអនុស្សារណៈនៃការ យោគយល់គ្នា តាមកាលបរិច្ឆេទដូចមានបញ្ជាក់ខាងលើ។

អនុស្សារណៈនៃការយោគយល់គ្នានេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលភាគីទាំងពីរបានចុះហត្ថ លេខានេះតទៅ។ អនុស្សារណៈនៃការយោគយល់គ្នានេះ ត្រូវធ្វើឡើងជាពីរភាសា គឺភាសាខ្មែរ និងភាសា អង់គ្លេស ដែលមានតម្លៃ និងសមត្ថកិច្ចស្មើគ្នា។

តំណាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**ឯកឧត្តម អ៊ុំ មាន**
រដ្ឋលេខាធិការ

តំណាងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់នៅកម្ពុជា

GESELLSCHAFT FÜR INTERNATIONALE ZUSAMMENARBEIT (GIZ) giz

**Adalbert Eberhardt**
នាយកប្រចាំប្រទេស, GIZ កម្ពុជា

**Dr. Monika Lüke**
អ្នកសម្របសម្រួលកម្មវិធី, GIZ កម្ពុជា

# MEMORANDUM OF UNDERSTANDING

## ON THE IMPLEMENTATION OF THE PROGRAMME IN CAMBODIA

**"SOCIAL AND LABOUR STANDARDS IN THE TEXTILE AND GARMENT SECTOR IN ASIA"**
(SLSG)

BETWEEN

MINISTRY OF LABOUR AND VOCATIONAL TRAINING
(MLVT)

AND

DEUTSCHE GESELLSCHAFT FÜR INTERNATIONALE ZUSAMMENARBEIT (GIZ) CAMBODIA
GIZ, SLSG PROGRAMME

Planned results are:

- Employees and the factory management including representatives from their relevant departments (e.g. HR, quality, etc.) meet regularly with the intention to implement labour and social standards, e.g. to raise information and awareness on the importance and advantages of implementing social and labour standards as recognised by the Cambodian government.
- Linkages between improved communication and worker management relation and their possible impact on productivity are examined through research and surveys which are commissioned jointly by MLVT and GIZ Cambodia.
- A strategy for more competitiveness, taking into account compliance with labour and social standards for the textile and garment sector in Cambodia is developed in consultation with relevant actors (ministry of labour and vocational training, ministry of commerce, employer and industry associations, trade unions).
- The weaknesses and needs of the MLVT are identified in order to establish a strong, effective and efficient Labour Inspection System to conduct labour inspection in the sector (Technology procedure skill).

## 3. GIZ Contribution

The Government of the Federal Republic of Germany shall provide GIZ Cambodia with a maximum amount of EUR 1,237,040.00 (one million two hundred thirty seven thousand and forty Euro). This amount shall include the costs incurred by GIZ in the course of the project implementation. By virtue of the nature of the technical cooperation, the fund will be managed by the GIZ country office in Cambodia.

**Provision of experts:**

GIZ Cambodia shall make available to the project:

- a seconded expert as Project Manager. This person will serve as Advisor to the MLVT and will coordinate and lead the missions of national Experts involved in this project.
- a national policy advisor and a national technical Coordinator.
- Short-term international and national Experts for studies, trainings and technical support .

**Basic and advanced trainings**

GIZ Cambodia shall organise trainings and study tours for MLVT officials and other relevant government institutions to strengthen their capacities, especially in regards to the implementation of social and labour standards and the establishment of a Labour Inspection System in the garment sector.

**Project equipment:**

Project equipment, in particular project vehicles, will be transferred to the MLVT, Department of Labour Inspection at the end of the project.

This Memorandum of Understanding is made on January 28, 2016 in Phnom Penh, Kingdom of Cambodia.

**BETWEEN**

**Ministry of Labour and Vocational Training** (Building No. 3, Russian Boulevard, Toek Laak, Toul Kork, Phnom Penh, Cambodia) hereinafter referred to as "MLVT".

**AND**

**Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH**
(Dag-Hammarskjoeld-Weg 1-5, 65760 Eschborn" hereinafter referred to as "GIZ Cambodia".

Concerning the project:
"Social and Labour Standards in the Textile and Garment Sector in Asia" hereinafter referred to as the "GIZ, SLSG Project".

## WHEREAS

The GIZ project "Social and Labour Standards in the Textile and Garment Sector in Asia"(GIZ, SLSG), wishes to support the Ministry of Labour and Vocational Training (MLVT), in their efforts to improve the working conditions in the textile and garment industry in Cambodia.

MLVT is ready and willing to accept such support from GIZ, SLSG in order to strengthen the Ministry's capacity in supporting the garment sector to become part of a healthy industry while in line with the Cambodian Industrial Development Policy 2015-2025 which aims to balance between the need of development and wellbeing of workers. The main contact person in the MLVT for communications with GIZ Cambodia shall be **Mr. Ouk Chantou, Director of Labour Inspection Department**, Email: ouk_chantou@yahoo.com.

## 1. Duration

The cooperation specified in this Memorandum will last from January 2016 to January 2018.

## 2. Project Objectives and Planned Results

The objectives of the cooperation are:

- The MLVT supports state and private actors in the application of suitable forms of information exchange, dialogue and cooperation at factory, as well as on national and regional level to support compliance with labour and social standards, which Cambodia has ratified and recognized.
- MLVT receives financial and technical support from GIZ Cambodia through this project to strengthen its capacities. The focus is thereby set on establishing an effective and efficient Labour Inspection System to be widely recognized. MLVT, with the support of the GIZ, SLSG project, is intended to make a substantial contribution towards the establishment of a trustworthy and transparent inspection system for the implementation of social and labour standards in the garment sector. This should strengthen the implementation of social and labour standards in the garment sector and eventually lead to better production.

**Operating and administrative costs**

GIZ Cambodia shall bear the operating and/or administrative costs associated with the processing of the German contribution to the Programme including the direct costs for the project implementation.

## 4. Contributions by the MLVT

MLVT is the main political partner of the Project in Cambodia and will act as the leading executive agency of the Project and has the right to demand the services from the GIZ Cambodia to which it is entitled.

MLVT will:

- Provide personnel to assist in the project implementation as link with international and national expert teams;
- Delegate staff members to participate in meetings of the Project;
- Facilitate access of GIZ Cambodia staff involved in the Project to other ministries and stakeholders as necessary for the implementation of the project;
- Facilitate experts' participation in training events and assist GIZ Cambodia in contacting participants relevant for the Project's objectives from other Cambodian institutions;
- Provide office space to the Project Coordinator at the MLVT; and
- Ensure coordination with the Social and Labour Standards project in Cambodia in general.

Both parties, MLVT, represented by **H.E. Mr. Oum Mean** and GIZ Cambodia represented by **Mr. Adelbert Eberhardt** and **Dr. Monika Lüke** shall sign the present Agreement on the dates indicated above with their respective signatures.

This Agreement shall enter into force on the date it is signed by both parties hereto. It shall be drawn up in two originals with the Khmer and the English version having both equal significance and authority.

For Ministry of Labour and Vocational Training of the Royal Government of Cambodia

**H.E. Mr. Oum Mean**
Secretary of State

For Deutsche Gesellschaft für Internationale Zusammenarbeit GmbH

**Adalbert Eberhardt**
Country Director, GIZ Cambodia

**Dr. Monika Lüke,**
Programme Coordinator, GIZ Cambodia